ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ១៩ សសរ

**សេចក្តីសម្រេច**
**ស្តីពី**
**ការបង្កើតគណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុក**
**រៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ | **អូន ព័ន្ធមុនីរ័ត្ន** | ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម | **ខៀវ កាញារីទ្ធ** | រដ្ឋមន្ត្រីក្រសួងព័ត៌មាន | អនុប្រធាន |
| ៣. ឯកឧត្តមបណ្ឌិត | **ជា វ៉ាន់ដេត** | រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | អនុប្រធាន |
| ៤. ឯកឧត្តម | **វង្សី វិស្សុត** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិតសភាចារ្យ | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. ឯកឧត្តមបណ្ឌិត | **អៀង ស៊ុនលី** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. ឯកឧត្តមបណ្ឌិត | **ផាន់ ផល្លា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨. ឯកឧត្តម | **ខូច មករា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៩. ឯកឧត្តម | **ហ្លួត ពុំ** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១០. ឯកឧត្តម | **លី វ៉ាន់ហុង** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុនៃក្រសួងព័ត៌មាន | សមាជិក |
| ១១. លោក | **អ៊ុង សិរីមង្គល** | មន្ត្រីជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | លេខាធិការ។ |

**ប្រការ២.-**

គណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ មានភារកិច្ចដូចខាងក្រោម÷

- ដឹកនាំ និងរៀបចំបង្កើតក្រុមហ៊ុនជាតិចម្រុះរវាងរដ្ឋ និងឯកជន ដើម្បីគ្រប់គ្រងថ្នាលទូរទស្សន៍ឌីជីថលជាតិ
- ផ្តល់គោលការណ៍ណែនាំសំខាន់ៗ សម្រាប់ការរៀបចំបង្កើតក្រុមហ៊ុនជាតិចម្រុះរវាងរដ្ឋ និងឯកជន ដើម្បីគ្រប់គ្រងថ្នាលទូរទស្សន៍ឌីជីថលជាតិ
- ផ្តល់គោលការណ៍ណែនាំសំខាន់ៗ សម្រាប់ការដកយកបន្ទារប្រេកង់ស៍ ៤៧០ ដល់ ៦៩៤ MHz ពីក្រុមហ៊ុនទូរទស្សន៍ឯកជន ដើម្បីយកមកប្រើប្រាស់សម្រាប់ថ្នាលទូរទស្សន៍ឌីជីថលជាតិ
- ផ្តល់គោលការណ៍ណែនាំសំខាន់ៗ សម្រាប់ការដកយកបន្ទារប្រេកង់ស៍សេសសល់ និងបន្ទារប្រេកង់ស៍ ៧០០ MHz មកជូនក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍គ្រប់គ្រង
- ពិនិត្យសម្រេចលើសំណើរបស់ក្រុមការងារបច្ចេកទេសក្នុងការរៀបចំបង្កើតក្រុមហ៊ុនជាតិចម្រុះរវាងរដ្ឋ និងឯកជន ដើម្បីគ្រប់គ្រងថ្នាលទូរទស្សន៍ឌីជីថលជាតិ
- រៀបចំរបាយការណ៍អំពីវឌ្ឍនភាពនៃការរៀបចំបង្កើតក្រុមហ៊ុនជាតិចម្រុះរវាងរដ្ឋ និងឯកជនសម្រាប់គ្រប់គ្រងថ្នាលទូរទស្សន៍ឌីជីថលជាតិ ដើម្បីគោរពជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ពិនិត្យសម្រេច និងណែនាំជាយថាហេតុដ៏ខ្ពង់ខ្ពស់ ។

**ប្រការ៣.-**

គណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ អាចប្រើប្រាស់មន្ត្រីក្រោមឱវាទរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីជួយសម្រួលការងារតាមការចាំបាច់ ។

**ប្រការ៤.-**

សមាសភាពនៃគណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធាន ។

គណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ មានសិទ្ធិអញ្ជើញភាគីពាក់ព័ន្ធ ចូលរួមប្រជុំតាមការចាំបាច់ ។

គណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងាររបស់ខ្លួន ។

**ប្រការ៥.-**

គណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ ត្រូវរៀបចំបង្កើតក្រុមការងារបច្ចេកទេសមួយ ដែលដឹកនាំដោយតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងកម្រិតរដ្ឋលេខាធិការ



ឋ

ព្រមទាំងមន្ត្រីជំនាញនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំ សម្របសម្រួលការងាររៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ ។

សមាសភាពជាក់ស្តែង និងភារកិច្ចលម្អិតនៃក្រុមការងារបច្ចេកទេសនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចមួយដោយឡែករបស់ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ ។

**ប្រការ៦.-**

គណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ អាចស្នើសុំកិច្ចសម្របសម្រួល និងកិច្ចសហប្រតិបត្តិការពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ របស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ ព្រមទាំងអាចប្រើប្រាស់យន្តការកិច្ចប្រជុំនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីពិភាក្សារកដំណោះស្រាយចំពោះកិច្ចការទាំងឡាយណា ដែលមិនអាចដោះស្រាយបានក្នុងកម្រិតបច្ចេកទេស ។

**ប្រការ៧.-**

តួនាទី និងភារកិច្ចរបស់គណៈកម្មាធិការចំពោះកិច្ចអន្តរក្រសួងទទួលបន្ទុករៀបចំបង្កើតថ្នាលទូរទស្សន៍ឌីជីថលជាតិ និងក្រុមការងារបច្ចេកទេស ដែលត្រូវបានកំណត់ក្នុងសេចក្តីសម្រេចនេះ នឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ នៅពេលក្រុមហ៊ុនថ្នាលទូរទស្សន៍ឌីជីថលជាតិ ត្រូវបានបង្កើត និងចាប់ផ្តើមដំណើរការ ហើយការងារដកហូត និងបែងចែកប្រេកង់ស័ត្រូវបានអនុវត្តរួច ។

**ប្រការ៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, រដ្ឋមន្ត្រីក្រសួងព័ត៌មាន, រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍, រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ សុក្រ ៨ រោច ខែ មាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ